Nº: 17-18
15-5-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ១៧_១៨ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ព្រះរាជក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

[illegible] ទីស្ដីការគណៈរដ្ឋមន្ត្រី [illegible]

Alt-Kimpo LAW

ក

មាតិកា

I – ខុទ្ទកាល័យព្រះមហាក្សត្រ

១- ព្រះរាជក្រឹត្យ

១៦-៤-១៩៩៧	ព្រះរាជក្រឹត្យ នស.រកត/០៤៩៧/២១ តែងតាំងលោក ចំន្ទ លី ជាឧកញ៉ា	១០១៨
២៥-៤-១៩៩៧	ព្រះរាជក្រឹត្យ នស/រកត/០៤៩៧/៣១ តែងតាំងលោក ស្រី សុម៉ាឈុ ជាឧកញ៉ា	១០១៩
១៤-៥-១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៧/១៧ តែងតាំងឯកឧត្តម អេង ឡោ ជាទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រីទី ២	១០២០
១៤-៥-១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៧/១៨ តែងតាំង ឯកឧត្តម ខ្មៅ ម៉ិច ជាទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រីទី ២	១០២១
១៤-៥-១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៧/១៩ តែងតាំងឯកឧត្តម ទូ គីមឆោរ ជាទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រីទី ២	១០២២
១៤-៥-១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៧/២០ តែងតាំង ឯកឧត្តម ហេង បូរិន្ទ ជាទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រីទី ២	១០២៣

II - រាជរដ្ឋាភិបាល

១- អនុក្រឹត្យ

១៥-៥-១៩៩៧	អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្ដីពីការផ្ទេរគុណធាននិងរបបឧបត្ថម្ភជីវភាពអនេ្តាវាសិក	១០២៤
១៥–៥-១៩៩៧	អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្ដីពីអាហារូបករណ៍ និង របបឧបត្ថម្ភជីវភាពអនេ្តាវាសិក	១០២៥
១៥-៥-១៩៩៧	អនុក្រឹត្យលេខ ៤៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១០២៩

១២-៥-១៩៩៧	អនុក្រឹត្យលេខ ៤៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	១០៣០
១២-៥-១៩៩៧	អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១០៣១
១២-៥-១៩៩៧	អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រី រាជការ	១០៣២
១៣-៥-១៩៩៧	អនុក្រឹត្យលេខ ៤៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រី រាជការ	១០៣៣
១៣-៥-១៩៩៧	អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរមុខងារ នាយទាហាន	១០៣៤

២- សេចក្ដីសំរេច

១០-៥-១៩៩៧	សេចក្ដីសំរេចលេខ ១៨ សសរ លុបចោលនូវសារាចរលេខ ៤៧៦ រ.ប ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ឯកឧត្ដម អ៊ុក វិធុន រដ្ឋលេខាធិការក្រសួងយុត្តិធម៌	១០៣៥
១៣-៥-១៩៩៧	សេចក្ដីសំរេចលេខ ១៩ សសរ ស្ដីពីការបង្កើតគណៈកម្មការចំរុះ ដោះស្រាយការកំណត់បរិវេណដី ស្ថានីយ៍វិទ្យុជាតិ ស្ទឹងមានជ័យ	១០៣៦
១៤-៥-១៩៩៧	សេចក្ដីសំរេចលេខ ២០ សសរ ស្ដីពីការតែងតាំងក្រុមការងារ សំរាប់ចរចាជាមួយភាគី ថៃ ក្នុងគំរោងសាងសង់វារីអគ្គិសនី ស្ទឹងមេទឹក (មណាម)	១០៣៩

III - ការងារបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១- ប្រកាស

១៤-៥-១៩៩៧	ប្រកាសលេខ ២៥៧ សហវ.ហ.ប្រក ស្ដីពីការប្រគល់សិទ្ធិចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ជូនមន្ត្រី ត្រួតពិនិត្យហិរញ្ញវត្ថុ	១០៤១

២- សេចក្ដីសំរេច

១៤-៥-១៩៩៧	សេចក្ដីសំរេចលេខ ០៣៥ សហវ.ហ ស្ដីពីការផ្ទេរភារកិច្ចគ្រប់គ្រងរោងចក្រ សហគ្រាសរដ្ឋ សហគ្រាសចំរុះរដ្ឋ	១០៤៥

៣- ប្រកាសអន្តរក្រសួង

ក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៧-៥-១៩៩៧ ប្រកាសរួមលេខ ១៨៧ ប្រក. សក ស្តីពីពន្ធលើការធ្វើដំណើរ នៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ១០៤៧

២- ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៦-៥-១៩៩៧ ប្រកាសលេខ ៤៣៤ ផក. ប្រក អនុញ្ញាតអោយក្រុមហ៊ុន យូពៀនហ្គាម៉ិន តំណាងដោយលោក CHAN MAN KAI ជនជាតិហុងកុង បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់សំរាប់នាំចេញ ១០៤៩

១២-៥-១៩៩៧ ប្រកាសលេខ ៤៤៣ ផក. ប្រក អនុញ្ញាតអោយលោក **អ៊ា ផុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតសំភារៈប្រើប្រាស់ពី ប្លាស្ទិក ១០៥០

១៣-៥-១៩៩៧ ប្រកាសលេខ ៤៤៤ ផក. ប្រក អនុញ្ញាតអោយលោក **ឡាស់ ឈីស** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ១០៥០

១៣-៥-១៩៩៧ ប្រកាសលេខ ៤៤៥ ផក. ប្រក អនុញ្ញាតអោយអ្នកស្រី **ស្វង គា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតនំបុ័ង ១០៥១

១៣-៥-១៩៩៧ ប្រកាសលេខ ៤៤៦ ផក. ប្រក អនុញ្ញាតអោយអ្នកស្រី **ទែង ឡៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតនំបុ័ង ១០៥១

១៣-៥-១៩៩៧	ប្រកាសលេខ ៤៤៧ ផក.ប្រក អនុញ្ញាតអោយលោក **គួយ ស្រេង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្ម ផលិតសរសៃគុយទាវ	១០៥២
១៣-៥-១៩៩៧	ប្រកាសលេខ ៤៤៨ ផក.ប្រក អនុញ្ញាតអោយលោក **តាន់ ម៉េងលី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្ម ផលិតថ្នាំលាប « សន្តិភាព »	១០៥២
១៣-៥-១៩៩៧	ប្រកាសលេខ ៤៤៩ ផក.ប្រក អនុញ្ញាតអោយលោក **លី ហេរ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិត ទឹកកកដើម	១០៥៣
១៣-៥-១៩៩៧	ប្រកាសលេខ ៤៥០ ផក.ប្រក អនុញ្ញាតអោយលោក **ម៉ុន រ៉ាត់ ម៉ុន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូច កិនដែក	១០៥៣
១៣-៥-១៩៩៧	ប្រកាសលេខ ៤៥១ ផក.ប្រក អនុញ្ញាតអោយលោក **សាំង គៅ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតទឹក ស៊ីអ៊ីវ ទឹកខ្មេះ	១០៥៤
១៣-៥-១៩៩៧	ប្រកាសលេខ ៤៥២ ផក.ប្រក អនុញ្ញាតអោយលោក **ហេង នុយ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ ក្បឿង	១០៥៤
១៣-៥-១៩៩៧	ប្រកាសលេខ ៤៥៣ ផក.ប្រក អនុញ្ញាតអោយលោក **កែវ ខាំ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិត ឥដ្ឋ- ក្បឿង	១០៥៥

៣- ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០៦-៥-១៩៩៧ ប្រកាសលេខ ១១១/៩៧ ពម.ប្រក អនុញ្ញាតជូនលោក **សុខ ឃាន** ផ្សព្វផ្សាយប័ណ្ណប្រកាស « ស្រាក្រហមរូបកីឡាកាស » ១០៥៦

០៨-៥-១៩៩៧ ប្រកាសលេខ ១១២/៩៧ ពម.ប្រក អនុញ្ញាតអោយផ្សាយឡើងវិញ និង ប្ដូរឈ្មោះ សារពត៌មាន «កំលាំងសេដ្ឋកិច្ចថ្មី» មកជាសៀវភៅ « Who is Who » ១០៥៧

០៨-៥-១៩៩៧ ប្រកាសលេខ ១១៣.៩៧ ពម/ប្រក អនុញ្ញាតអោយលោក **ឈុយ ខៀង** បើកអាជីវកម្មទូរទស្សន៍ ខ្សែកាប នៅទីក្រុងរតនគីរី ១០៥៩

០៩-៥-១៩៩៧ ប្រកាសលេខ ១១៤/៩៧ ពម.ប្រក អនុញ្ញាតជូនក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍បោះពុម្ពផ្សាយសៀវភៅកម្រងតែមប្រើ ១០៦០

១៥-៥-១៩៩៧ ប្រកាសលេខ ១២១/៩៧ ពម.ប្រក អនុញ្ញាតជូនលោក **ឈឺ លៀងស៊ុន** បើកអាជីវកម្មទូរទស្សន៍ រលកធាតុអាកាសប្រព័ន្ធ MM DS ១០៦១

៤- ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

០៦-៥-១៩៩៧ ប្រកាសលេខ ៣៤៤ អយក.ប្រក ស្ដីពីការប្ដូរទីតាំងសាលាបឋមសិក្សា « **ស្វរគោរសេក** » មកដាក់នៅកណ្ដាលមណ្ឌល អូរឧកញ៉ាហេង វិញ ១០៦២

០៧-៥-១៩៩៧ ប្រកាសលេខ ៣៥៣ អយក.ប្រក ស្ដីពីការ ប្ដូរឈ្មោះសាលាបឋម

	សិក្សា « កណ្ដៀងរាយ » មកជាសាលាបឋមសិក្សា «ម៉ុង សំផន កណ្ដៀងរាយ »	១០៦៣
០៧-៥-១៩៩៧	ប្រកាសលេខ ៣៥៤ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សាសម្ដេច ហ៊ុន សែន ចាំយាម	១០៦៥
០៧-៥-១៩៩៧	ប្រកាសលេខ ៣៥៥ អយក.ប្រក ស្ដីពីការ ាប់សាលាឧបសម្ព័ន្ធ « ខ្នុលត្រាច » មកជាសាលាបឋម ក្សា សេឡេលក្ខណៈ រិញ	១០៦៦
០៧-៥-១៩៩៧	ប្រកាសលេខ ៣៥៦ អយក.ប្រក ស្ដីពីការប ាះសាលាបឋមសិក្សា « រំលក » មកជាសាលាបឋមសិក្ស ទ័សន រំលក	១០៦៨
០៧-៥-១៩៩៧	ប្រកាសលេខ ៣៥៧ អយក.ប្រក ស្ដីពីការ ្មាះសាលាបឋមសិក្សា ពងទឹក មកជាសាលាបឋមសិក្សា ៉ខ អំ សេដ្ឋា ពងទឹក »	១០៧០
០៩-៥-១៩៩៧	ប្រកាសលេខ ៣៦២ អយក.ប្រក ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅភាសាខ្មែរ « សំរាប់សិស្សថ្នាក់ទី ២ »	១០៧១
០៩-៥-១៩៩៧	ប្រកាសលេខ ៣៦៣ អយក.ប្រក ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគណិតវិទ្យា « សំរាប់សិស្សថ្នាក់ទី ២ »	១០៧២
០៩-៥-១៩៩៧	ប្រកាសលេខ ៣៦៤ អយក.ប្រក ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅជីវវិទ្យា « សំរាប់គ្រូថ្នាក់ទី ៨ »	១០៧៤
០៩-៥-១៩៩៧	ប្រកាសលេខ ៣៦៥ អយក. បក ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅភាសាខ្មែរ « សំរាប់គ្រូថ្នាក់ទី ៨ »	១០៧៥
១៥-៥-១៩៩៧	ប្រកាសលេខ ៣៧៣ អយក.ប្រក ស្ដីពីការ បើកវិទ្យាល័យចំណោះទូទៅឯកជន « ស្មីបាត់ដំបង » ស្ថិតក្នុងឃុំ ស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង	១០៧៦

៥- ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

០៥-៥-១៩៩៧ ប្រកាសលេខ ១៨០ ប្រក.កសក.ចត ស្តីពីការបំបែកការិយាល័យ ១០៧៨

៦- ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០៦-៥-១៩៩៧ ប្រកាសលេខ ០៧៦ បទ.ប្រក ស្តីពីតម្លៃស្ថាបនាក្លី និង ផ្ទេរប្រព័ន្ធ
ទូរគមនាគមន៍ ១០៧៩

៧- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

១- ប្រកាស

០២-៥-១៩៩៧ ប្រកាសលេខ ២៣២ ប្រក.មស ស្តីពីការបែងចែកមន្ត្រី រាជការ ១០៨១
០២-៥-១៩៩៧ ប្រកាសលេខ ២៣៣ ប្រក.មស ស្តីពីការបង្កើតអង្គភាព អាស៊ាន ១០៨៣

២- សេចក្តីសំរេច

១៥-៥-១៩៩៧ សេចក្តីសំរេចលេខ ២៦១ សសរ.មស.ក្រខ ស្តីពីការតែងតាំង
សិស្ស និស្សិត ចំនួន ១៦ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅ
ប្រទេស ១០៨៤

៨- ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

០៨-៥-១៩៩៧ សេចក្តីសំរេចលេខ ៩១/៩៧ កធស អនុញ្ញាតអោយបើកសាខា
ស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមសេវេនដេយ
អាត់វេនទីស្ត នៃព្រះវិហារឈ្មោះ « សេវេនដេយអាត់វេនទីស្ត
បុសមេឃ » នៅឃុំ ជើងទៀន ស្រុកចុងកាល់ ខេត្តសៀមរាប ១០៨៧
០៨-៥-១៩៩៧ សេចក្តីសំរេចលេខ ៩២/៩៧ កធស. អនុញ្ញាតអោយបើកសាខា
ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត « ក្រុមសេវេនដេយអាត់វេនទីស្ត »
នៃព្រះវិហារឈ្មោះ សេវេនដេយអាត់វេនទីស្ត ភូមិអូរក្រឡាញ់

	ឃុំក្រឡាញ់ ស្រុក ក្រឡាញ់ ខេត្ត សៀមរាប ។	១០៨៩
០៨-៥-១៩៩៧	សេចក្តីសំរេចលេខ ៩៣/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ « ក្រុមសេវេនដេយអាត់វេនទីស្ទ » នៃព្រះវិហារឈ្មោះ « សេវេនដេយអាត់វេនទីស្ទ ស្ថិតនៅភូមិ តាកាំ ឃុំ ដូនកែវ ស្រុក ពួក ខេត្ត សៀមរាប	១០៩១
០៨-៥-១៩៩៧	សេចក្តីសំរេចលេខ ៩៤/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិយសម្ពន្ធគ្រិស្តបរិស័ទ នៃព្រះវិហារឈ្មោះ « សម្ពន្ធកិច្ច ប្រេសប៊ីធីរានខ្មែរ » ស្ថិតនៅផ្ទះលេខ ១៤៤ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក	១០៩[illegible]
០៨-៥-១៩៩៧	សេចក្តីសំរេចលេខ ៩៥/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិយសម្ពន្ធ គ្រិស្តបរិស័ទកម្ពុជា នៃព្រះវិហារឈ្មោះ « វិសិលីយាន » ស្ថិតនៅផ្ទះលេខ ៤៤២ B ផ្លូវព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន	១០៩៤
០៨-៥-១៩៩៧	សេចក្តីសំរេចលេខ ៩៦/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិយសម្ពន្ធ គ្រិស្តបរិស័ទកម្ពុជា នៃព្រះវិហារឈ្មោះ « ព្រះវិហារ និង បណ្ណាល័យដំណឹងល្អ » ស្ថិតនៅផ្ទះលេខ ១៣៩EO ផ្លូវលេខ ២១៧ សង្កាត់អូរឫស្សីទី ៣ ខណ្ឌ ៧ មករា	១០៩៦
០៨-៥-១៩៩៧	សេចក្តីសំរេចលេខ ៩៧/៩៧ ធេស អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមសហព័ន្ធ គ្រិស្តបរិស័ទខ្មែរ នៃព្រះវិហារឈ្មោះ [illegible] បើកស្នាក់ការ ១៨EO ផ្លូវលេខ ២៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ	១០៩៨

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត

/០៤៩៧/២១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ច័ន្ទ លី

ជា

ឧកញ៉ា

ប៉េកាំង ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៧/៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ស្រី សូម៉ាណា

ជា

ឧកញ៉ា

ប៉េកាំង ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៧
ព្រះហស្តលេខា
នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៥៩៧/១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **តេង ឡៅ** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការកៅស៊ូ មានឋានៈស្មើអនុរដ្ឋលេខាធិការ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៧/១៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឌិក ម៉ុង** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកពតិមានវិទ្យា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០៥៩៧/១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ឌូ គីមឆោរ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការសុខាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៧/២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ហេង បូរិន្ទ** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការកលយុទ្ធ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II- រាជរដ្ឋាភិបាល

១- អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៧ អនក្រ.បក

ស្តីពីការផ្ទេរឥណទាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៥អនក្រ. ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរឥណទាន ពីជំពូក៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន៣.៧២៤លានរៀល (បីពាន់ប្រាំពីររយម្ភៃបួនលានរៀលគត់) មកជំពូក៣២ (អន្តរាគមន៍ ក្នុងវិស័យអន្តរជាតិ) ក្នុងថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ។

មាត្រា ២ : ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីចាត់វិធានការផ្នែក ហិរញ្ញវត្ថុ អោយបានទាន់ពេលវេលាសំរាប់ប្រទេសកម្ពុជា ដែលត្រូវជាសមាជិក អាស៊ាន ក្នុងឆ្នាំ ១៩៩៧ ខាងមុខនេះ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថ - លេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា — ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ : ១៨ អនក្រ.បក

ស្តីពី

អាហារូបករណ៍ និង របបឧបត្ថម្ភជីវភាពអន្តេវាសិក

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស–៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស–រកត–១០៩៤–៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស–រកត–១០៩៤–៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស–រកម–០១៩៦–០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំយុវជននិងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

សម្រេច

មាត្រា ១ : អាហារូបករណ៍ប្រចាំខែរបស់សិស្សនិងនិស្សិត ដែលបានបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់តាមកំរិតដូចមានខាងក្រោម ÷

- ក្រោមឧត្តមសិក្សា : ១២.០០០៛
- ឧត្តមសិក្សា : ១០.០០០៛
- មធ្យមសិក្សាឯកទេស : ៩.០០០៛
- បឋមសិក្សាឯកទេស : ៨.០០០៛

របបឧបត្ថម្ភអន្តេវាសិកនេះ ត្រូវអនុវត្តចាប់តាំងពីខែមីនា ឆ្នាំ១៩៩៧ នេះតទៅ ។

មាត្រា ២ : ការផ្តល់អាហារូបករណ៍ប្រចាំខែត្រូវអនុវត្តតែក្នុងរយៈពេលកំពុងសិក្សា ។ ពេលឈប់សំរាកក្នុងឱកាសមហាវិស្សមកាល និងពេលព្យួរការសិក្សា សិស្ស និស្សិតមិនត្រូវបានទទួលប្រាក់អាហារូបករណ៍ឡើយ ។

ក្នុងករណីសិស្ស និស្សិតរៀនគ្រូគថ្នាក់ រដ្ឋនឹងផ្តាច់អាហារូបករណ៍វិញលើកលែង តែសិស្ស និស្សិត ដែលស្ម័គ្រចិត្តធ្វើគ្រូ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សានោះ ។

មាត្រា ៣ : ចំនួនសិស្ស និស្សិត ដែលត្រូវទទួលអាហារូបករណ៍ ត្រូវកំណត់ដូចតទៅ ÷

ក– នៅតាមគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស :

– កំរិតក្រោយឧត្តមសិក្សា : ៥០ ភាគរយ

– កំរិតឧត្តមសិក្សា : ១០ ភាគរយ

– កំរិតមធ្យមសិក្សាឯកទេស : ២០ ភាគរយ

– កំរិតបឋមសិក្សាឯកទេស : ៣៥ ភាគរយ

– និស្សិតកំរិតក្រោយឧត្តមសិក្សា និងឧត្តមសិក្សា ការកំណត់អត្រាអាហារូបករណ៍ ៥០ភាគរយ និង ១០ភាគរយ នឹងត្រូវអនុវត្តពីឆ្នាំសិក្សា១៩៩៦–៩៨ តទៅ ចំពោះនិស្សិតដែលទើបប្រលងជាប់ ថ្មី។

–និស្សិតក្រោយឧត្តមសិក្សា និងឧត្តមសិក្សា ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សានានា ត្រូវបានទទួលអាហារូបករណ៍ប្រចាំខែ តាមកំរិតដូចក្នុងមាត្រា១ តាមអត្រាភាគរយចាស់ គឺ ១០០ភាគរយ និង៣០ភាគរយ រហូតដល់បញ្ចប់ការសិក្សារបស់ខ្លួន ។

–សិស្ស និស្សិត មធ្យមសិក្សាឯកទេស និងបឋមសិក្សាឯកទេស ត្រូវអនុវត្តតាមស្មារតីអនុក្រឹត្យថ្មីនេះ។

ខ–ផ្នែកបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កំរិតសិក្សា ផ្នែកកីឡា និង សៀក ត្រូវបានទទួលអាហារូបករណ៍មួយរយភាគរយ ។

មាត្រា ៤ : អាទិភាពក្នុងការផ្តល់អាហារូបករណ៍

ការផ្តល់អាហារូបករណ៍ ត្រូវអនុវត្តតាមគោលការណ៍អាទិភាពដូចខាងក្រោម ÷

១– សិស្ស និស្សិត គោរពវិន័យបានល្អ និង រៀនពូកែ

២– កូនកំព្រាឪពុក ម្តាយ និង មានជីវភាពរស់នៅជួបការលំបាកខ្លាំង

៣– កូនជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល

៤– កូនកសិករក្រ និង កូនមន្ត្រីរាជការដែលឪពុក ម្តាយមានជីវភាពរស់នៅជួបការលំបាក ។

–ក្នុងអាទិភាពទាំង៤ ខាងលើ នារីភេទត្រូវបានយកចិត្តទុកដាក់មុនគេ ។

មាត្រា ៥ : ការកំណត់ឈ្មោះ សិស្ស និស្សិត ដែលត្រូវបានទទួលអាហារូបករណ៍ និង ការពិនិត្យ វាយតំលៃផ្តល់អាទិភាពដូចក្នុងមាត្រា៣ និង មាត្រា ៤ ខាងលើត្រូវធ្វើមួយឆ្នាំម្តងដោយក្រុមប្រឹក្សា វិន័យរបស់សាលា ។

មាត្រា ៦ : ចំពោះមន្ត្រីអ្នករាជការគ្រប់ប្រភេទ ដែលស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតអោយទៅចូលរួមសិក្ខាសាលាធ្វើក្រឹតការ សុក្រឹតការ ឬ បំប៉នមុខជំនាញផ្សេងៗ រយៈពេលពីមួយ " ០១ " ថ្ងៃដល់ " ១០ " ថ្ងៃត្រូវទទួលប្រាក់ស្នាក់នៅ និង បេសកកម្មតាមច្បាប់រដ្ឋ ។ រយៈពេលសិក្សាចាប់ ពីដប់មួយ " ១១ " ថ្ងៃរហូតដល់តិចជាងដប់ពីរ " ១២ " ខែ ត្រូវទទួលប្រាក់ឧបត្ថម្ភអន្តេវាសិកចំនួន "២.០០០៛" ក្នុងមួយថ្ងៃ ។ ចំពោះសិក្ខាកាមដែលមានលំនៅដ្ឋាននៅជិតអាចទៅមកស្នាក់នៅផ្ទះ របស់ខ្លួនបានត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន " ១.០០០៛ " ក្នុងមួយថ្ងៃ ។

មាត្រា ៧ : សិស្សជនជាតិភាគតិច និង សិស្សមានជីវភាពក្រលំបាកខ្លាំង នៅតំបន់ដាច់ស្រយាល ដែលរដ្ឋបានកំណត់ ហើយដែលមកសិក្សានៅក្នុងអន្តេវាសិកដ្ឋាន នៃ អនុវិទ្យាល័យ វិទ្យាល័យ ឬទីប្រជុំជនស្រុក ឃុំ ដែលមានអន្តេវាសិកដ្ឋានត្រូវបានទទួលប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃម្នាក់ៗចំនួន មួយពាន់ " ១.០០០៛ " រៀល និងរបបឧបត្ថម្ភសំរាប់សំភារៈដំណេក និង សំភារៈសិក្សាប្រចាំឆ្នាំក្នុង ម្នាក់ៗចំនួនប៉ែតសិបពាន់បីរយរៀល "៨០.៣០០៛" រៀល ។

មាត្រា ៨ : ក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចណែនាំអនុវត្តអនុក្រឹត្យនេះ ។ អនុក្រឹត្យ សេចក្តីសំរេច និងបទបញ្ជាទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ គ្រឹះស្ថាន

ឧត្តមសិក្សា និងសិក្សាឯកទេសទាំងអស់ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗ ខ្លួនអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ : ៤៤ អនក្រ.បក

ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

ប្រការ ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនលោក LIU CHIN MU អគ្គនាយកក្រុមហ៊ុន LAN SONG INTERNATIONAL Co. LTD ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ១០៥.០០០ ដុល្លារ សហរដ្ឋអាមេរិក ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការស្តារ និងកសាងប្រទេសជាតិ ។

ពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៩៧

អនុក្រឹត្យលេខ : ៤៦ អនក្រ.ជត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សមាគមឥស្លាមកម្ពុជា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៦ រូប ដែលបានបរិច្ចាគថវិកាសរុបចំនួន ២.០០០.០០០ ដុល្លារអាមេរិក សំរាប់ជួយកសាងមជ្ឈមណ្ឌលឥស្លាមសំរាប់ចិញ្ចឹមកុមារកំព្រានៅក្នុងខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ

និង ជួយកសាងជួសជុល សាលារៀន វិហារ អណ្ដូងទឹក និង បង្គន់អនាម័យ នៅតាមខេត្តមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជាដូចមានរាយនាមខាងក្រោម នេះ :

១-លោក តារីក សាមុី អាល់អុីសា ជនជាតិអារ៉ាប់ កូវ៉ែត
បរិច្ចាគទឹកប្រាក់ ៧០០.០០០ ដុល្លារអាមេរិក

២-លោក ហ្សាម៉ាល់ យូសុះអាល់ហាដាត ជនជាតិអារ៉ាប់កូវ៉ែត
បរិច្ចាគទឹកប្រាក់ ៥០០.០០០ ដុល្លារអាមេរិក

៣-លោក ហុីស្សាម មូហាំម៉ាត់ បូការីស្ស ជនជាតិអារ៉ាប់កូវ៉ែត
បរិច្ចាគទឹកប្រាក់ ៤០០.០០០ ដុល្លារអាមេរិក

៤-លោកវេជ្ជបណ្ឌិត មូហាំម៉ាត់ ខាលីហ្វាស់ អាល់តាមុីមុី ជនជាតិអារ៉ាប់សេអ៊ូត
បរិច្ចាគទឹកប្រាក់ ៣០០.០០០ ដុល្លារអាមេរិក

៥-លោក មូហាំម៉ាត់ ពិន យូសុះ ជនជាតិខ្មែរ ឥស្លាម
បរិច្ចាគទឹកប្រាក់ ៥០.០០០ ដុល្លារអាមេរិក

៦-លោក អាប់ឌុលឡោះ អុីប៉ាហុីម អាល់ហាទី ជនជាតិស៊ូដង់
បរិច្ចាគទឹកប្រាក់ ៥០.០០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សមាគមឥស្លាម កម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ: ៤៧ អនក្រ.តត

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា១— ត្រូវបានតែងតាំងលោក **ឃុន ជីវកេន** ជាប្រធាននាយកដ្ឋានទូទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា២— សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៤៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោក **សុ ឈារី** និង លោក **ម៉ែន រុន** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី ទី ២ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៤៩ អនក្រ.តត

ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារនាយនាយកដ្ឋាន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោកវរសេនីយ៍ទោ **លឹម សាងសេ** និង លោកវរសេនីយ៍ទោ **ហ៊ុន ស៊ីថា** ជាសមាជិកក្រុមលេខា សម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមាន ឋានន្តរសក្តិជា វរសេនីយ៍ឯក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតនេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៨ សសរ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងលិខិតពិគ្រោះរបស់សម្តេចនាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៧
- យោងលិខិតឆ្លើយរបស់ក្រុមប្រឹក្សាអ្នកច្បាប់ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : លុបចោលនូវសារាចរលេខ ៤៧៦ រប ៩៧ ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ឯកឧត្តម **អ៊ុក ទិឌុន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ។

ប្រការ ២ : ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរបស់ខ្លួន ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានអនុភាព អនុវត្តចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៩ សសរ

ស្តីពីការបង្កើតគណៈកម្មការចំរុះដោះស្រាយ

ការកំណត់ព្រំប្រទលដីស្ថានីយ៍ទិន្នជាតិ ស្ទឹងមានជ័យ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– តាមស្មារតីអង្គប្រជុំអន្តរក្រសួងនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះ ដោះស្រាយការកំណត់បរិវេណដីស្ថានីយវិទ្យុជាតិ ស្ទឹងមានជ័យ ដែលមានសមាសភាព ៖

១–ឯកឧត្តម **ឧុង កានុន** សហរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
២–ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** ក្រសួងពត៌មាន សមាជិក
៣–ឯកឧត្តម **ជ្រឹម ប៉េខហុង** អភិបាលរងរាជធានីភ្នំពេញ សមាជិក
៤–ឯកឧត្តម តំណាងក្រសួងមហាផ្ទៃ សមាជិក
៥–ឯកឧត្តម តំណាងក្រសួងការពារជាតិ សមាជិក
៦–លោកប្រធាននាយកដ្ឋានសុរិយោដី នៃទីស្តីការគណៈរដ្ឋមន្ត្រី លេខាធិការ
៧–លោកប្រធាននាយកដ្ឋានអប់រំ វប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី លេខាធិការ

ប្រការ ២ : គណៈកម្មការចំរុះ ដែលចែងក្នុងប្រការ ១ មានភារកិច្ច ៖

– សិក្សាស្រាវជ្រាវរាល់បញ្ហា ដែលពាក់ព័ន្ធជុំវិញបរិវេណស្ថានីយវិទ្យុជាតិស្ទឹងមានជ័យ និង ដីស្ថាប័ន អង្គភាព អាគារសាធារណៈនានា និងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដែលមានលើទីតាំងបង្គោលអង់តែនវិទ្យុជាតិស្ទឹងមានជ័យ។
– កំណត់បានទូវផ្ទៃដី សំរាប់វិទ្យុស្ទឹងមានជ័យ ដោយយោលទៅលើលក្ខណៈបច្ចេកទេស ព្រមទាំងធានាសុវត្ថិភាពលើការផ្សព្វផ្សាយ ។
–បូកសរុបសភាពការណ៍ និងវិភាគលើលក្ខណៈបច្ចេកទេសនេះ ដើម្បីលើកជាវិធានការអនុវត្ត ថ្វាយ និង ជូនគណៈរដ្ឋមន្ត្រីសំរេច ។

ប្រការ ៣ : គណៈកម្មការចំរុះនេះមានសិទ្ធិបង្កើតក្រុមការងារមួយសំរាប់ជំនួយការងារ ដែលមានសមាសភាព ៖

១–លោកប្រធាននាយកដ្ឋានស៊ីវិលយោធា ទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២–លោកប្រធាននាយកដ្ឋានអប់រំ វប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣–លោកតំណាងសាលាក្រុងភ្នំពេញ	សមាជិក
៤–លោកតំណាងក្រសួងពតិមាន	សមាជិក
៥–លោកតំណាងក្រសួងមហាផ្ទៃ	សមាជិក
៦–លោកប្រធានការិយាល័យស៊ីវិលយោធាក្រុងភ្នំពេញ	សមាជិក
៧–លោកតំណាងសាលាខ័ណ្ឌមានជ័យ	សមាជិក

ប្រការ ៤ : ក្រុមការងារ ដែលចែងក្នុងប្រការ ៣ មានភារកិច្ច ÷

– ចុះសិក្សាស្រាវជ្រាវ កត់ត្រាចំនួនអាគារសាធារណៈ លំនៅដ្ឋានរបស់ប្រជាពលរដ្ឋ វាស់វែង និង គូរព្រាងនូវព្រំប្រទល់ដី លក្ខណៈបច្ចេកទេសផ្នែកវិទ្យុ ផ្ញើកតិរោងលំជាប់អាទិភាពនៃសំណង់នានា ដែលអាចសាងសង់បាននៅក្នុងបរិវេណដីស្ថានីយ៍វិទ្យុជាតិ ស្ទឹងមានជ័យ និង វាយតំលៃហេតុប៉ះពាល់ផ្នែកបច្ចេកទេសវិទ្យុ និងផលប្រយោជន៍ក្នុងការប្រើប្រាស់ដីធ្លីនៅតំបន់នេះ ។

– បូកសរុបរាយការណ៍ ពីសភាពការណ៍នានាក្នុងបរិវេណស្ថានីយ៍ វិទ្យុជាតិស្ទឹងមានជ័យ និងលើកវិធានការអនុវត្តជូនគណៈកម្មការចំរុះដែលចែងក្នុងប្រការ ១ ។

ប្រការ ៥ : សមាជិកគណៈកម្មការចំរុះ និង សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយត្រូវចុះធ្វើសកម្មភាពអោយបានជាបន្ទាន់បំផុត ។

– គណៈកម្មការចំរុះនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរួលការងារ ។

– គណៈកម្មការនេះ ត្រូវរំសាយជាស្វ័យប្រវត្តិ ក្រោយពីការសំរេចជាស្ថាពររបស់រាជរដ្ឋាភិបាល លើករណីនេះ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពតិមាន ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និង ឯកឧត្តម អស់លោក ដែលមានឈ្មោះនៅក្នុងប្រការ ១ និង

ប្រការ ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី ទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២០ សសរ

ស្តីពីការតែងតាំងក្រុមការងារសំរាប់ចរចាជាមួយភាគីថៃក្នុងគំរោង

សាងសង់វារីអគ្គិសនីស្ទឹងមេទឹក(មណាម)

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញអនុក្រឹត្យលេខ១១អនក្រ ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់សំណង់វារីអគ្គិសនីស្ទឹងមេទឹក(មណាម)

– តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការការងារអន្តរក្រសួងមួយ ដើម្បីធ្វើការចរចាជាមួយភាគីថៃ ក្នុងគំរោងកិច្ចសហប្រតិបត្តិការសាងសង់វារីអគ្គិសនីស្ទឹងមេទឹក (មណាម) ។

ប្រការ ២ : សមាសភាពគណៈកម្មការនេះ មានដូចខាងក្រោម ÷

១–ឯកឧត្តម **ឃី តាំងលីម** អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គ ប្រធាន

២–ឯកឧត្តម **អ៊ិត ប្រាំង** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អនុប្រធាន

៣–លោក **សយ សុខា** ប្រធាននាយកដ្ឋានផែនការ ពាណិជ្ជកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

ប្រការ ៣ : គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចរៀបចំគំរោងឯកសារនានា ស្តីពីការសាងសង់វារីអគ្គិសនីស្ទឹងមេទឹក(មណាម)ដើម្បីយកទៅធ្វើការចរចាជាមួយភាគីថៃ រួចធ្វើរបាយការណ៍ពីលទ្ធផលនៃការចរចា ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិទន្លេមេគង្គ និងបណ្តាស្ថាប័នពាក់ព័ន្ធ មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
ឧង្គត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III- ការងារបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៥៧ សហវ.ប្រក

ស្ដីពីការប្រគល់សិទ្ធចុះទិដ្ឋាការលើអាណត្តិបើកប្រាក់

ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ**នរោត្ដម សីហនុ វរ្ម័ន** ១០៩៤-៨៣ នស រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- យោងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- យោងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស រកម ១២៩៦-៣៨ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតការ ត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- យោងប្រកាសលេខ ០៤៨ ប្រក.សហវ.ហ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ អង្គការត្រួតពិនិត្យហិរញ្ញវត្ថុ
- យោងប្រកាសលេខ ២៩៩ ប្រក.សហវ.ហ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៦ ស្តីពីសិទ្ធចុះទិដ្ឋា ការលើអាណត្តិបើកប្រាក់
- យោងតំរូវការចាំបាច់ក្នុងកិច្ចអនុវត្តការត្រួតពិនិត្យ ហិរញ្ញវត្ថុ តាមផែនការកែទំរង់ហិរញ្ញវត្ថុសាធារណៈ

សំរេច

ប្រការ ១ : អនុលោមតាមបទបញ្ញានៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរេចប្រគល់សិទ្ធ ចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ជូនមន្ត្រី ត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង រដ្ឋលេខាធិការដ្ឋាន និង ស្ថាប័នរដ្ឋបាលកណ្តាល លើកលែងតែមន្ត្រីត្រួតពិនិត្យអមក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខជាតិ ។

ប្រការ ២ : កំរិតខ្ពស់បំផុត នៃឥណទានថវិកាដែលមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មានសិទ្ធចុះទិដ្ឋាការ លើអាណត្តិបើកប្រាក់មានចំនួនចាប់ពី ២០ «ម្ភៃ » លានរៀលចុះ ដូចមានចែង ក្នុងប្រការ ៦.១ នៃប្រកាសលេខ ២៩៩ ប្រក.សហវ.ហ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៦ ។

ប្រការ ៣ : លក្ខខណ្ឌទូទៅនៃកិច្ចប្រតិបត្តិការ ដែលមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ទាំងឡាយដូចមានចែងក្នុងប្រការ ៧ និង ៩ នៃប្រកាស ២៩៩ ប្រក.សហវ.ហ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៦ ក្នុងនោះ :

១-ចំនួនថវិកាមិនកំណត់«លើសពី ២០ លានរៀល »ចំពោះតែ :

*ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងថ្លៃឈ្នួលពលករអណ្តែតដែលមាន ច្បាប់អនុញ្ញាត និងមានទិដ្ឋាការយល់ព្រមដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

*ប្រាក់កំរៃលើសម៉ោងក្នុងកម្មវត្ថុវិធីការងារ ដែលមានគោលការណ៍អនុញ្ញាត និងត្រឹមត្រូវតាមគោល របបហិរញ្ញវត្ថុ ។

* ចំណាយអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ រួមមាន :
- ចំណាយសង្គមកិច្ចផ្ទាល់«ជំពូក ៣១–០១–០១ ....»
- ចំណាយអាហារូបករណ៍«ជំពូក ៣១–០១–០២........................»

ដែលមានរបបត្រឹមត្រូវតាមលក្ខណ៍ការណ៍ហិរញ្ញវត្ថុ និង លិខិតយុត្តិការភ្ជាប់តាមមានបញ្ជាក់ច្បាស់លាស់ពីក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសាមី ។

២–ឯកសារស្នើចំណាយគ្រប់ជំពូកថវិកា ក្រៅពីខ្ទឹមសារកំណត់ក្នុងចំណុច លើ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធពេញលេញក្នុងការត្រួតពិនិត្យ និង ចុះទិដ្ឋាការធានាចំណាយក្នុងរង្វង់ឥណទានថវិកាក្រោម ២០ លានរៀល ។

៣–ឯកសារស្នើចំណាយដែលមានចំនួនថវិកាលើសពី២០លានរៀល រួមទាំងសម្ភារៈចំណាយក្រៅគំរោងអនុម័ត និង មានភាពស្មុគស្មាញ ត្រូវបានធ្វើការត្រួតពិនិត្យពីភាពត្រឹមត្រូវលើគ្រប់ លិខិតយុត្តិការភ្ជាប់តាម ក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ដូចក្នុងមាត្រា៧ នៃអនុក្រឹត្យលេខ ៨១ អន.ក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាននិងស្ថាប័នរដ្ឋបាលកណ្តាល ត្រូវលើកមតិយោបល់ជូននាយកដ្ឋានហិរញ្ញកិច្ច ដើម្បីធ្វើការពិនិត្យ និង មានវិធានការដោះស្រាយឬ លើកបណ្តឹងមតិ ជូនថ្នាក់ដឹកនាំក្រសួងសំរេច តាមលក្ខណ៍ការណ៍ហិរញ្ញវត្ថុ ។

ប្រការ ៤ : បន្ថែមលើមុខងារត្រួតពិនិត្យចំណាយថវិការដ្ឋ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក៏មាន កិច្ចការមួយផ្សេងទៀត ជំនួយដល់នាយកដ្ឋាន គឺត្រួតពិនិត្យនិងជំរុញការបង់ចំណូលចូលថវិការដ្ឋ ។

ប្រការ ៥ : ក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង របស់នាយកដ្ឋានហិរញ្ញកិច្ច ដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ នៃប្រកាសលេខ ០៤៨ ប្រក.សហវ.ហ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

ប្រការ ៦ : នាយកដ្ឋានហិរញ្ញកិច្ចមានភារកិច្ចចាំបាច់ក្នុងការទទួលខុសត្រូវ និង ត្រួតពិនិត្យអំពីយន្តការ និងនិតិវិធីនៃកិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋសំដៅអនុវត្តអោយបាននូវការងារសំខាន់ៗពីរ នោះគឺ :

១- ប្រមូលផ្តុំពត៌មានលើកិច្ចសន្យាចំណាយ និងការប្រើប្រាស់ឥណទានថវិកាអោយស៊ីសង្វាក់ និង កម្មវិធីចំណូល ចំណាយប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២- ធ្វើរបាយការណ៍រួមស្តីពីស្ថានភាព និង លទ្ធផលនៃកិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋតាមកាលកំណត់ ដោយផ្អែកតាមតួលេខរាយការណ៍របស់ក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ ។

ប្រការ ៧ : ក្នុងពេលអនុវត្តប្រកាសនេះ ប្រសិនមានជួយការលំបាកដោយប្រការណាមួយ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវពិភាក្សាជាមួយថ្នាក់ដឹកនាំនាយកដ្ឋាន ដើម្បីពិនិត្យដោះស្រាយ ឬលើកយោបល់សុំការណែនាំពីថ្នាក់ដឹកនាំក្រសួង ដូចមានខ្លឹមសារបញ្ជាក់ក្នុងប្រការ ១២ នៃប្រកាសលេខ ២៩៩ ប្រក.សហវ.ហ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៦ ។

ប្រការ ៨ : ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគ និងស្ថាប័នមូលដ្ឋាន រតនាគារជាតិ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុគ្រប់ក្រុម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០៣៥ សហវ.ហ

ស្តីពីការផ្ទេរភារកិច្ចគ្រប់គ្រង

រោងចក្រ - សហគ្រាសរដ្ឋ - សហគ្រាសចំរុះរដ្ឋ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល លេខ នស រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត ការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ
- បានឃើញច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈដែល ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម ០៦៩៦.០៣ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៦

- បានឃើញប្រកាស ស្តីពីការរៀបចំអង្គការត្រួតពិនិត្យហិរញ្ញវត្ថុ លេខ ០៤៨ ប្រក.សហវ ចុះថ្ងៃទី ១៩-១-៩៦
- បានឃើញសារាចរណែនាំស្តីពីវិន័យថវិកាចលនាឥណទាន លេខ ០០៧ សហវ.ម ចុះថ្ងៃទី ១១-៣-៩៦
- យោងតាមការចាំបាច់ក្នុងការគ្រប់គ្រងរោងចក្រ សហគ្រាសរដ្ឋនិងសហគ្រាសចំរុះរដ្ឋនាដំណាក់ កាលបច្ចុប្បន្ន

សម្រេច

ប្រការ ១ : កិច្ចការគ្រប់គ្រងរោងចក្រ សហគ្រាសរដ្ឋ សហគ្រាសចំរុះរដ្ឋ គឺជាភារកិច្ចរបស់នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ។

ប្រការ ២ : នាយកដ្ឋានហិរញ្ញកិច្ចមានភារកិច្ចផ្ទេរ និង ប្រគល់សំណុំរឿងដែលពាក់ព័ន្ធ នឹងការងារគ្រប់គ្រងសហគ្រាសដូចមានចែងក្នុងប្រការ ១ ខាងលើ ជូននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋអោយបានឆាប់រហ័សលោស់ និង គ្រប់គ្រាន់ ដើម្បីធ្វើជាមូលដ្ឋានសំរាប់គ្រប់គ្រងបន្ត ។

ប្រការ ៣ : នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ មានភារកិច្ចត្រួតពិនិត្យនិងប្រមូលចំណូលទាំងអស់ពីបណ្តារោងចក្រ-សហគ្រាសដូចក្នុងប្រការ ១ ។

ប្រការ ៤ : នាយកដ្ឋានហិរញ្ញកិច្ច (មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ) បន្ថែមលើមុខងារសំខាន់ដូចបានចែងក្នុងប្រកាស ស្តីពីការរៀបចំអង្គការត្រួតពិនិត្យហិរញ្ញវត្ថុ លេខ ០៤៨ ប្រក-សហវ-ហ ចុះថ្ងៃទី ២៤ -៩៦ និងសារាចរណែនាំស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលេខ ០០៥ សហវ-ហ-សរណន ចុះថ្ងៃទី ២៤ -២-៩៦ នៅមានភារកិច្ចជំរុញអោយបង់ចំណូលតាមច្បាប់ថវិកាប្រចាំឆ្នាំ ។

ប្រការ ៥ : រាល់សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : ខុទ្ទកាល័យទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធមានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

៣- ប្រកាសអន្តរក្រសួង

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសរួមលេខ ១៨៧ ប្រក.សក

ស្តីពីពន្ធលើការធ្វើដំណើរនៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង

* * *

អន្តរក្រសួង

ក្រសួងសាធារណការ និង ដឹកជញ្ជូន និង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១០-៩៤/៩០ ចុះថ្ងៃទី ៣១-១០-១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

– យោងសេចក្តីសំរេចរបស់ម៉ោយប្រជុំពេញគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៩ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : កំណត់ថ្ងៃពន្ធលើការធ្វើដំណើរនៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង តាមអត្រាដូចខាងក្រោមនេះ :

១– ចំពោះអ្នកដំណើរជនជាតិបរទេស :

ក–ថ្ងៃសេវាលើអ្នកដំណើរ លើការហោះហើរអន្តរជាតិ ២០$ (ម្ភៃ) ដុល្លារអាមេរិក

ខ–ថ្ងៃសេវាលើអ្នកដំណើរ លើការហោះហើរក្នុងស្រុក ១០$ (ដប់)ដុល្លារអាមេរិក

២– ចំពោះអ្នកដំណើរជាតិខ្មែរ ដែលរស់នៅកម្ពុជា :

ក–ថ្ងៃសេវាលើអ្នកដំណើរ លើការហោះហើរអន្តរជាតិ ១៥$ (ដប់ប្រាំ) ដុល្លារអាមេរិក

ខ–ថ្ងៃសេវាលើអ្នកដំណើរ លើការហោះហើរក្នុងខេត្តផ្សេងៗ ៤$ (បួន) ដុល្លារ អាមេរិក

ប្រការ ២ : ប្រកាសនេះ និង ចូលជាធរមានក្នុងរយៈពេល ៣ ខែ ក្រោយពីថ្ងៃចុះហត្ថលេខា ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយនឹងប្រកាសនេះ ទុកជានិរាករណ៍ ។

ប្រការ ៤ : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយកនៃក្រសួងទាំងពីរ ត្រូវទទួលបន្ទុកតាមភារកិច្ចរៀងៗ ខ្លួន អនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ។

ទេសរដ្ឋមន្ត្រី	ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
គាត ឈន់	**អ៊ឹង ហ៊ួត**

* * *

២- នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤៣៤ ឧក.ប្រក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន យូញៀន ហ្គារម៉ិន (ខេមបូឌា) (UNION GARMENT) (CAMBODIA) CO, LTD) តំណាងដោយលោក CHAN MAN KAI ជនជាតិ ហុងកុង ភេទប្រុស អាយុ ៤០ឆ្នាំ អាស័យដ្ឋាន ROOM 1215-17 ELITE IND CENTER 883 CHENG SHA KOWLOON-HONG KONG កាន់លិខិតឆ្លងដែនលេខ ៦១១៩០២៤១៧ ចុះថ្ងៃទី ១៣-៤-១៩៩៥ «បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ» ដែលមានឈ្មោះថា «រោងចក្រយូញៀន ហ្គារម៉ិន ខេមបូឌា» មានទីតាំងស្ថិតនៅភូមិក្បាលដំរី សង្កាត់កាកាប ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រ ត្រូវធ្វើនៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល អោយបានសំរេចរយៈក្នុងពេល ០៦ ខែ ដោយ រាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតផលរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផល «សម្លៀកបំពាក់គ្រប់ប្រភេទ» ទៅ តាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរ:

ប្រកាសលេខ ៤៤៣ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ឹក ផុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៩៦៤១ ភ.ព ចុះថ្ងៃទី ២៣-១១-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២២០០ ផ្លូវលេខ ៩៤ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការ ឧស្សាហកម្មតូចផលិតសំភារៈប្រើប្រាស់អំពីប្លាស្ទិច នៅក្នុងទីតាំង ផ្ទះលេខ ៩ ផ្លូវលេខ ២៨៧ សង្កាត់បឹងកក់ទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **អ៊ឹក ផុន** ត្រូវបានអនុញ្ញាតអោយផលិតនូវសំភារៈប្រើប្រាស់អំពីប្លាស្ទិច សញ្ញា «GOLDED WARE» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
អ៊ិត ប្រាំង

* * *

ប្រកាសលេខ ៤៤៤ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនផលិតទឹកកកដើម ដែលមានលោក **ឡាស់ លីស** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩២៨០៨ ប.ប ចុះថ្ងៃទី ០២-៨-៩០ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ១៩ ភូមិគម្មករ ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៥ ផក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សុខ គា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១៩៣ ប.ប ចុះថ្ងៃទី ២៦_៩_៩៣ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៣៤ ភូមិវត្តល្វៀប ឃុំចំការ សំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការឡផលិតនំប៉័ង នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះដល់ពាល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៦ផក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ខែម ឡឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១២៥២៨ ប.ប ចុះថ្ងៃទី ២០_០១_៨៦ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៣៥ ភូមិ ១៣មករា ឃុំព្រែក ព្រះស្តេច ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរ ការឡផលិតនំប៉័ង នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

: ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

ល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៧ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **គួយ ស្រេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៨១៦៨ ប.ប ចុះថ្ងៃទី ១៣_៣_៨៦ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ១៤ ភូមិផ្កាស្លា ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការសិប្បកម្មផលិតសរសៃគុយទាវ នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៨ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **តាន់ ម៉េងលី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៧១២៣ ភ.ព ចុះថ្ងៃទី ១៤_០១_៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៥៨ ផ្លូវលេខ ១៩៩ សង្កាត់ទួលស្វាយព្រៃទី១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម ឧស្សាហកម្មតូចផលិត ថ្នាំលាប «សន្តិភាព » នៅក្នុងទីតាំង ដីឡូត៍គ្មានលេខ ក្រុមទី៣ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **តាន់ ម៉េងលី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើផលិតផល ចំនួន ០២ ម៉ាកសញ្ញាគឺថ្នាំលាបសញ្ញា «ផ្កាឈូក » និងថ្នាំលាបសញ្ញា «ផែនដីលេខ ១ » ស្របតាមគំរូ ផ្លាកសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៩ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក លី ហោ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៥៨២៩ ភ.ព ចុះថ្ងៃទី ១១–៣–៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៨៦អឺ១ហ្សិត ផ្លូវលេខ ២១៧ សង្កាត់អូរឫស្សីទី៤ ខ័ណ្ឌ ។ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើមនៅក្នុងដីឡូត៍គ្មានលេខផ្លូវលេខ ៣៦៩ ភូមិ ទឹមចាន់ សង្កាត់ច្បារអំពៅទី ២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៥០ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក ទ៉ាត់ ម៉ិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣២៨៨៧ ភ.ព ចុះថ្ងៃទី ០៥–៤–៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៣០៧ ផ្លូវជាតិលេខ ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចកិនដែក នៅក្នុងទីតាំងដូចអាស័យ ដ្ឋានខាងលើ ។

២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៥១ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សាំង តៅ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៩៦៧៦ ភ.ព ចុះថ្ងៃទី ២១-៣-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិវត្តលៀប ឃុំ ចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ-ទឹកខ្មេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **សាំង តៅ** ត្រូវបានអនុញ្ញាតអោយបន្តផលិតនូវមុខផលិតផលទឹកស៊ីអ៊ីវសញ្ញា «រថភ្លើង ១ » ទឹកស៊ីអ៊ីវសញ្ញា «រថភ្លើង ២ » និងទឹកខ្មេះសញ្ញា «ទន្សាយកាន់ផ្លែក្រូច »ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៥២ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង ឌុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៦៩២៧ ប.ប ចុះថ្ងៃទី ២៣-១០-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរតាគាំ ២ ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការ

សិប្បកម្មឡឥដ្ឋ-ក្បឿង នៅក្នុងទីតាំងភូមិ អណ្តូងចេញ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤៥៣៥ក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្មផលិតឥដ្ឋ-ក្បឿង ដែលមានលោក កែវ ខាំ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៥៥២១ ប.ប ចុះថ្ងៃទី ០៥-៦-៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិ ២០ឧសភា ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរ ការផលិតកម្ម នៅក្នុងទីតាំងភូមិ អង់ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរ

* * *

៣- ឱស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១១១/៩៧ ពម.ប្រក

* * *

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ន.ស.រ.ក.ម ចុះថ្ងៃទី ២៤.០១.៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
- យោងប្រកាសអនុញ្ញាតលេខ ១២០ ផ.ក.ប្រ.ក ចុះថ្ងៃទី ១២.០២.៩៧ របស់ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- យោងលិខិតសំណើសុំអនុញ្ញាតច្បាប់ផ្សព្វផ្សាយប័ណ្ណប្រកាស «ស្រាក្រហមរូបកីឡាកាស» ចុះថ្ងៃទី ២០.០២.១៩៩៧ របស់លោក **សុខ ឃាន**

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **សុខ ឃាន** ស្ថិតនៅផ្ទះលេខ ៤៥២ ផ្លូវជាតិលេខ ០៥ ឃុំ គ.ម ៦ ស្រុកឬស្សីកែវ រាជធានីភ្នំពេញ ផ្សព្វផ្សាយប័ណ្ណប្រកាស «ស្រាក្រហមរូបកីឡាកាស» ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយប័ណ្ណប្រកាសនេះ ត្រូវអនុវត្តតាមកិច្ចសន្យាដោយរក្សាអោយបានតាមទំរង់ច្បាប់ដើម ទាំងខ្លឹមសារ និងរូបភាពដែលបានតម្កល់ទុកនៅក្រសួងពតិមាន និងត្រូវគោរពរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គមតាមអាជ្ញាធរដែនដីកំណត់អោយបិទផ្សាយ ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍នៃក្រសួងពត៌មាន មន្ទីរពត៌មានខេត្ត–ក្រុង និងអាជ្ញាធរដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១១២/៩៧ ពម.ប្រក

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស រកម ០៨៩៥–០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ១៩៩៥ ។

– បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ២២៨/៩៣ពម ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការអនុញ្ញាតអោយសារពត៌មាន «កំលាំងសេដ្ឋកិច្ចថ្មី» បោះពុម្ពចែកផ្សាយដោយមានលោក ម៉ែន ណារ៉ុង ជាចាងហ្វាងការផ្សាយ និង ប្រកាសបិទលេខ ១៣៤/៩៥ពម.ប្រក ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៥ ។

– បានឃើញសំណើសុំផ្សាយឡើងវិញ និងសុំប្តូរឈ្មោះសារពត៌មានពី «កំលាំងសេដ្ឋកិច្ចថ្មី» មកជាសៀវភៅ « Who is Who » ជាភាសាអង់គ្លេស វិញ របស់លោក **ម៉ែន ណារ៉ុង** ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ១៩៩៧ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយចេញផ្សាយឡើងវិញ និង ប្តូរឈ្មោះសារពត៌មាន «កំលាំងសេដ្ឋកិច្ចថ្មី» មកជាសៀវភៅ « Who is Who » ជាភាសាអង់គ្លេស ផ្សាយតែដំណឹងក្រុមហ៊ុនក្នុង និងក្រៅប្រទេសវិញ ដោយមានលោក ម៉ែន ណារ៉ុង ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៩C ផ្លូវ ៥១ សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកសារពត៌មាន ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ត្រូវប្រគល់សៀវភៅចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសនឹងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយ ខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងនាយកការផ្សាយសៀវភៅ « Who is Who » ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ៣ ឆ្នាំ ហើយសេចក្តីណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១១៣/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងព័ត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រម ន.ស.រ.ក.ម ចុះថ្ងៃទី ២៤.០១.៩៦ ច្បាប់ស្តីពីការ

– យោងលិខិតស្នើសុំអនុញ្ញាតបើកអាជីវកម្មទូរទស្សន៍ខ្សែកាប ចុះថ្ងៃទី ២៣ ខែ ៤ ឆ្នាំ ១៩៩៧ របស់លោក **ឈុយ ខៀង**

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឈុយ ខៀង** សញ្ជាតិកម្ពុជា ទីលំនៅបច្ចុប្បន្ន សង្កាត់ឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី បើកអាជីវកម្មទូរទស្សន៍ខ្សែកាប សំរាប់បំរើការអោយអតិថិជននៅទីក្រុងរតនគិរី ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ទូរទស្សន៍ខ្សែកាបនេះ ត្រូវគោរពតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិ បទបញ្ជា ឬសេចក្តីណែនាំខាងផ្នែកសោតទស្សន៍នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍នៃក្រសួងព័ត៌មាន ប្រធានមន្ទីរព័ត៌មានខេត្តរតនគិរី និង អាជ្ញាធរដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១១៤/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤.០១.៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតសំណើសុំអនុញ្ញាតបោះពុម្ពផ្សាយ ចុះថ្ងៃ ២៤.៤.១៩៩៧ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សំរេច

ប្រការ ១ : អនុញ្ញាតជូនក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ បោះពុម្ពផ្សាយសៀវភៅកំរងតែមប្រៃ ដោយមានលេខតម្កល់ ០០៣/៩៧ ព.ម.ប.ស.ទ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ១៩៩៧។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សព្វផ្សាយ ត្រូវអនុវត្តតាមគំរូដើម ដែលបានដាក់ជូនក្រសួងពត៌មានពិនិត្យ និងសំរេច ។ ចំពោះសៀវភៅដែលបានបោះពុម្ពរួច ហើយត្រូវយកមកតម្កល់ទុកចំនួន ១៥ ក្បាល នៅក្រសួងពត៌មាន និង ២ ក្បាលទៀត នៅបណ្ណាល័យជាតិ ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ ត្រូវទទួលទោសតាមច្បាប់ ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍នៃក្រសួងពត៌មាន មន្ទីរពត៌មានរាជធានីភ្នំពេញ និង អាជ្ញាធរដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១២១/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០១៩៦_១៤ នស/រកម ចុះថ្ងៃទី ២៤.០១.៩៦ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- យោងសំណើសុំអនុញ្ញាតបើកអាជីវកម្មទូរទស្សន៍រលកធាតុអាកាស ប្រព័ន្ធ MMDS របស់លោក **លី សៀវស៊ុន** ចុះថ្ងៃទី ១២_៥_១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **លី សៀវស៊ុន** ស្ថិតនៅផ្ទះលេខ ១៨៥អឺ២ ផ្លូវលេខ ១ ក្រុម ៤២ សង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មទូរទស្សន៍រលកធាតុអាកាសប្រព័ន្ធ MMDS សំរាប់បន្តជាវអោយអតិថិជននៅតាមខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍នេះ ត្រូវគោរពតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិ បទបញ្ជា ឬ សេចក្តីណែនាំខាងផ្នែកសោតទស្សន៍នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តបទល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍នៃក្រសួងព័ត៌មាន ប្រធានមន្ទីរខេត្ត-ក្រុង អាជ្ញាធរដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
សឿង មុលី

* * *

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៤៤ អយក.ប្រក

ស្តីពីការប្តូរទីតាំងសាលាបឋមសិក្សា «អូរតាសេក »

មកដាក់នៅ «កណ្តាលមណ្ឌលអូរឧកញ៉ាហេង » វិញ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជននិងកីឡា ក្រុងព្រះសីហនុ លេខ ៤៣ អយក.សន ចុះថ្ងៃទី ២០-០១-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាក្រុងព្រះសីហនុ ប្តូរទីតាំងសាលាបឋមសិក្សា «អូរតាសេក» ដែលពីមុនមានទីតាំងស្ថិតនៅភូមិអូរតាសេក សង្កាត់អូរឧកញ៉ាហេង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មកដាក់នៅ «កណ្តាលមណ្ឌលអូរឧកញ៉ាហេង» សង្កាត់អូរឧញ៉ាហេង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុវិញ ចាប់តាំងពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាអូរតាសេក ត្រូវរក្សាឯកសារប៉ុន្មានគ្រប់គ្រង និង រក្សាឈ្មោះដើមដដែល ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រធានមន្ទីរក្រសួងអប់រំយុវជននិងកីឡា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការៈហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាក្រុងព្រះសីហនុ ប្រធានការិយាល័យ អប់រំយុវជននិងកីឡាខ័ណ្ឌព្រៃនប់ នាយកសាលាបឋមសិក្សាអូរតាសេក មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
គាំ សាឃន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៥៣ អយក.ប្រក

ប្រកាស

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «គរណ្ឌក្រៃរាយ »
មកជាសាលាបឋមសិក្សា «ម៉ុង សំផន_គរណ្ឌក្រៃរាយ »

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី ១៦-០៩-៩៦ [illegible]
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជននិងកីឡា ខេត្តស្វាយរៀង ចុះថ្ងៃទី ១៨-០១-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាខេត្តស្វាយរៀង ប្តូរឈ្មោះសាលាបឋមសិក្សា«**កណ្តៀងរាយ**»មកជា «សាលាបឋមសិក្សា **ម៉ឹង សំផន-កណ្តៀងរាយ**» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦-១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តស្វាយរៀង ប្រធានការិយាល័យអប់រំ យុវជននិងកីឡាស្រុកស្វាយទាប នាយកសាលាបឋមសិក្សា ម៉ឹង សំផន-កណ្តៀងរាយ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាវាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៥៤ អយក.ប្រក

ប្រកាស

ស្តីពីការបើកសាលាបឋមសិក្សា ហ៊ុន សែន ចាំយាម

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជននិងកីឡាខេត្តកោះកុង ចុះថ្ងៃទី ០៥-០២-៩៧ ដែលមានចំណារឯកភាពរបស់ឯកឧត្តមអភិបាលខេត្ត ចុះថ្ងៃទី ២៥-០២-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាខេត្តកោះកុង បើកសាលាថ្មីមួយកន្លែងពេញលក្ខណៈ មានឈ្មោះថា សាលាបឋមសិក្សា **សម្តេច ហ៊ុន សែន ចាំយាម** ដែលមានទីតាំងស្ថិតនៅភូមិចាំយាម ឃុំមណ្ឌលសីមា ស្រុកមណ្ឌលសីមា ខេត្តកោះកុង ចាប់តាំងពីឆ្នាំសិក្សា ១៩៩៦ - ១៩៩៧ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា **សម្តេច ហ៊ុន សែន ជ័យឈ្នះ** ត្រូវដឹកនាំដោយនាយក មួយរូប និងនាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តកោះកុង ប្រធានការិយាល័យ អប់រំ យុវជននិងកីឡាស្រុកមណ្ឌលសីមា នាយកសាលាបឋមសិក្សា **សម្តេច ហ៊ុន សែន ជ័យឈ្នះ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

តា សាមាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៥៥ អយក. ប្រក

ប្រកាស

ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ «ទួលត្នោត»

មកជា សាលាបឋមសិក្សា «ពេញលក្ខណៈ» ថ្មី

* *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦–៧–៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ថ្នាក់

– បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ស្ពឺលេខ ៨៥៦ អយក. ចុះថ្ងៃទី ១៧–១២–៩៦

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាខេត្តកំពង់ស្ពឺ ផ្លាស់សាលាឧបសម្ព័ន្ធ «ទួលត្រាច» ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងបី ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦– ១៩៩៧ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា «ទួលត្រាច » ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តកំពង់ស្ពឺ ប្រធានការិយាល័យ អប់រំយុវជននិងកីឡាស្រុកគងពិសី នាយកសាលាបឋមសិក្សា «ទួលក្រាប » មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាឃាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៥៦ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «រំលក »

មកជាសាលាបឋមសិក្សា ហ៊ុន សែន រំលក

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦_៧_៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញលិខិតស្នើសុំរបស់ព្រះគ្រូចៅអធិការវត្ត ប្រធានគណៈកម្មការសាងសង់ និងប្រធានសមាគមមាតាបិតាសិស្សសាលាបឋមសិក្សា «រំលេក» ចុះថ្ងៃទី ១៥_០២_៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាខេត្តតាកែវ ប្តូរឈ្មោះសាលាបឋមសិក្សា «**រំលេក** » ដែលមានទីតាំងស្ថិតនៅក្នុងឃុំចារស្រែ ស្រុកអង្គរបុរី ខេត្តតាកែវ មកជាសាលាបឋមសិក្សា «**ហ៊ុន សែន- រំលេក**» វិញ ចាប់តាំងពីឆ្នាំសិក្សា ១៩៩៦_ ១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តតាកែវ ប្រធានការិយាល័យ អប់រំ យុវជននិងកីឡាស្រុកអង្គរបុរី នាយកសាលាបឋមសិក្សា **ហ៊ុន សែន- រំលេក** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាហាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៥៧ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ពងទឹក»

មកជាសាលាបឋមសិក្សា «ជៀង អ៊ំ.សេដ្ឋា.ពងទឹក»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញលិខិតស្នើសុំរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ពងទឹក ចុះថ្ងៃទី ២៨-០១-៩៧ និងចំណាររបញ្ជូនរបស់អភិបាលរងនៃខេត្តស្វាយរៀង លេខ ៧៨ស.កិ ចុះថ្ងៃទី ១៨-០២-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាខេត្តស្វាយរៀង ប្តូរឈ្មោះសាលាបឋមសិក្សា «**ពងទឹក**» ដែលមានទីតាំងស្ថិតនៅ ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង មកជាសាលាបឋមសិក្សា «**ជៀង អ៊ំ. សេដ្ឋា ពងទឹក**» វិញ ចាប់តាំងពីឆ្នាំសិក្សា ១៩៩៦- ១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តស្វាយរៀង ប្រធានការិយាល័យអប់រំ យុវជននិងកីឡាស្រុករំដួល នាយកសាលាបឋមសិក្សា «**ជៀវ អ៊ំ. សេដ្ឋាពងនីក** » មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សារាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៦២ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅភាសាខ្មែរ

«សំរាប់សិស្សថ្នាក់ទី ២ »

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទឆ. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅភាសាខ្មែរសំរាប់សិស្សថ្នាក់ទី២ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅភាសាខ្មែរសំរាប់សិស្សថ្នាក់ទី ២ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការភាសាខ្មែរបឋមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជននិងកីឡា និងរៀបរៀងដោយលោក **ឈី សុមុនី** ដើម្បី ប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
ហត្ថលេខា និងត្រា
តុល ឡោះ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៦៣ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគណិតវិទ្យា

«សំរាប់សិស្សថ្នាក់ទី២ »

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_៩៤
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅគណិតវិទ្យាសំរាប់សិស្សថ្នាក់ទី ២ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅគណិតវិទ្យាសំរាប់សិស្សថ្នាក់ទី ២ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការគណិតវិទ្យាបឋមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជននិងកីឡា និង រៀបរៀងដោយលោក **ចាន់ ពន** ដើម្បីប្រើប្រាស់នៅតាមសាលារៀនបំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានបំណេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

ហត្ថលេខា និងត្រា

តូច ឡោះ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៦៤ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅជីវវិទ្យា

«សំរាប់គ្រូថ្នាក់ទី៨»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅជីវវិទ្យា សំរាប់គ្រូថ្នាក់ទី ៨ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅជីវវិទ្យា សំរាប់គ្រូថ្នាក់ទី ៨ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការជីវវិទ្យាមធ្យមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជននិងកីឡា និងរៀបរៀងដោយអ្នកស្រី **នាង សោភ័ណ** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានកិច្ចការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិងមធ្យមសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៦៥ អយក. ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅភាសាខ្មែរ

«សំរាប់គ្រូថ្នាក់ទី ៨»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ

- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅភាសាខ្មែរ សំរាប់គ្រូថ្នាក់ទី ៨ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅភាសាខ្មែរសំរាប់គ្រូថ្នាក់ទី ៨ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការភាសាខ្មែរនៃកម្មវិធីសិក្សានៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជននិងកីឡា និងរៀបរៀងដោយលោក **លី សុម្មនី** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានបាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលបោះពុម្ពផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
ហត្ថលេខា និងត្រា
តុល ឡោះ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៧៣ អយក.ប្រក
ស្ដីពីការបើកវិទ្យាល័យចំណេះទូទៅ ឯកជន«រស្មីបាត់ដំបង»
ស្ថិតក្នុងឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្ដីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៤/៤២ ចុះថ្ងៃទី ២៦ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន ។
- យោងលិខិតស្នើសុំរបស់លោក ទូ ចាំង ចុះថ្ងៃទី ០៤ មិថុនា ១៩៩៦ ស្តីពីការបើកវិទ្យាល័យចំណេះទូទៅឯកជន ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និងកីឡានិងអភិបាល ខេត្តបាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកវិទ្យាល័យចំណេះទូទៅឯកជន ដែលមានឈ្មោះថា វិទ្យាល័យ **ស្ទើបាត់ដំបង** ចាប់ពីឆ្នាំសិក្សា ១៩៩៦_៩៧ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវអនុវត្តកម្មវិធីសិក្សា និង សៀវភៅសិក្សាគ្រប់មុខវិជ្ជា ដែលក្រសួងអប់រំ យុវជន និងកីឡាបានអនុញ្ញាត ។

ប្រការ ៣ : លោក **ទូ ចាំង** ត្រូវដឹកនាំគ្រប់គ្រង និងចាត់តាំងគណៈគ្រប់គ្រងវិទ្យាល័យ និងគ្រូបង្រៀនដែលមានបច្ចេកទេសគរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយបានត្រឹមត្រូវតាមស្មារតីអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលាចំណេះទូទៅឯកជន ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកវិទ្យាល័យបេសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាឃាន

* * *

៥- ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ១៨០ ប្រក.កសក.ចត

ស្តីពីការបំបែកការិយាល័យ

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម. ០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ .
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- តាមសំណូមពររបស់ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកណ្តាល

សំរេច

ប្រការ ១ : ត្រូវបានបំបែកការិយាល័យជលផល - រុក្ខាប្រមាញ់ ជាពីរការិយាល័យនៅចំណុះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្តកណ្តាល គឺ :

១_ការិយាល័យ រុក្ខាប្រមាញ់

២_ការិយាល័យជលផល

ប្រការ ២ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យទាំងពីរខាងលើ អាស្រ័យដោយមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ខេត្តកណ្តាលរៀបចំកំណត់ ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : អគ្គនាយកក្រសួង នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការស្ថិតិ ប្រធាននាយកដ្ឋាន គណនេយ្យ–ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ប្រធាននាយកដ្ឋានជលផល និង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួ

* * *

៦-ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

ប្រកាសលេខ : ០៧៦ បន.ប្រក

ស្តីពីតម្លៃស្លាបនាថ្មី និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

– បានឃើញព្រះរាជក្រមលេខ នស.រកម.០៤៩៦_២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

– បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុម ប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ
- បានឃើញកំណត់ហេតុអង្គប្រជុំនាថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីតម្លៃស្ថាបនាថ្មី និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍

សំរេច

ប្រការ ១ : កំណត់តម្លៃស្ថាបនាថ្មី និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍ដូចមានជូនភ្ជាប់នូវតារាងតម្លៃស្ថាបនាថ្មី និងផ្ទេរប្រព័ន្ធទូរគមនាគមន៍ ។

ប្រការ ២ : ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ជាអ្នកទទួលរ៉ាប់រងផ្គត់ផ្គង់សំភារៈបរិក្ខារទាំងអស់ក្នុងការស្ថាបនាទូរស័ព្ទថ្មី ។ ដោយឡែកការផ្ទេរប្រព័ន្ធទូរគមនាគមន៍ អតិថិជនអាចបន្តប្រើបរិធានទូរស័ព្ទចាស់ដដែល ។

ប្រការ ៣ : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន តាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

I- តម្លៃស្ថាបនាថ្មី និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍ :

	ទូរស័ព្ទ	ទូរពុម្ព
-ស្ថាបនាទូរស័ព្ទថ្មី..............................	២២០ ដុល្លារ	
-បរិធានទូរស័ព្ទ និង សំភារៈស្ថាបនា...........	៧០ -	
-ស្ថាបនាទូរពុម្ពថ្មី..............................		៤០០ ដុល្លារ
-ផ្ទេរទីកន្លែងក្នុងអាគារតែមួយ	១០ -	២០ -
-ផ្ទេរទីកន្លែង « អាស័យដ្ឋានថ្មី »..............	៨០ -	១៥០ -

_ប្តូរលេខទូរស័ព្ទថ្មី (ប្រព័ន្ធដូចគ្នា ឬខុសគ្នា) ....៤០ _		
_ទូរស័ព្ទប្រើលេខរួម	២០ _	
_ការប្តូរលេខទូរស័ព្ទប្រើលេខរួម	២០ _	
_ផ្អាកប្រើប្រាស់បណ្តោះអាសន្នរយៈពេល៣ខែ...	២០ _	៤០ _
II_ប្រាក់ធានាតំកល់ទុក :		
_សេវាអន្តរជាតិ	២០០ ដុល្លារ	២០០ ដុល្លារ
_សេវាក្នុងប្រទេស	៦០ _	
III _ថ្លៃជួលជាវប្រចាំខែ		
_ទូរស័ព្ទ_ទូរសារ	១៥ ដុល្លារ	៧ ដុល្លារ
_ទូរពុម្ព « តេឡិច »		៨០
Service faci lity	០២ _	
Itemized Bill (Local)	០៣ _	៣ _

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

៧- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

១- ប្រកាស

ភ្នំពេញ , ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ២៣២ ប្រក.មស

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

_ បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិ បាលកម្ពុជា
- បានឃើញការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ២រូប សំរាប់ទទួលបន្ទុកភារកិច្ច សហប្រតិបត្តិការអន្តរជាតិអាស៊ាន នៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយមានរាយនាមដូចខាងក្រោមនេះ :

១_លោក **អ៊ឹក សំបូរ** អនុប្រធាននាយកដ្ឋាននីតិកម្ម

២_លោក **នូ សុចន្ថា** អនុប្រធាននាយកដ្ឋានក្របខ័ណ្ឌ

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានក្របខ័ណ្ឌ នាយកដ្ឋានបៀវត្ស និងសាមីខ្លួនមានភារកិច្ចអនុវត្តតាមប្រកាស នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

ភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៣៣ ប្រក.មស

ស្តីពី

ការបង្កើតអង្គភាពអាស៊ាន

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

ប្រការ ១ : ត្រូវបានបង្កើតអង្គភាពអាស៊ាន (ASEAN UNIT) អោយស្ថិតនៅចំណុះនៅរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ។

ប្រការ ២ : អង្គភាពអាស៊ាន (ASEAN UNIT) មានភារកិច្ចវិភាគ និងគ្រប់គ្រងការងារអាស៊ាននានា ដែលទាក់ទិនផ្ទាល់ទៅនឹងរដ្ឋលេខាធិការដ្ឋានមុខ ងារសាធារណៈ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានក្របខ័ណ្ឌ នាយកដ្ឋានបៀវត្ស មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ធ្នាក់ សុខ

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ២៦១ សសរ.មស.ក្រខ

ស្តីពី

ការបែងចែកសិស្ស និស្សិតចំនួន ១៦ នាក់

ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតលេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨ ខែ ០២ ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រកិត ១ ចំនួន ០២ នាក់ ថ្នាក់ឧត្តមចំនួន ១៣នាក់ ថ្នាក់មធ្យមចំនួន ០១នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវ

បានបែងចែកអោយទៅបំពើការងារនៅតាមក្រសួង ស្ថាប័នមួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និង ផ្តល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំពើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហ្វាក់ ...

* * *

តារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ២៦១ សសរមស.គ្រខ

ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៨៧ ស្តីពីការបែងចែកនិស្សិតចំនួន ១៦ នាក់

ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

* * * * *

ល.រ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃ ខែ ឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញបច្ចេកទេស	បៀវត្ស	ប្រភពបណ្តុះបណ្តាល
	១_ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំនួន ០៦ នាក់						
	ក_អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រក៏តែ ១ ចំនួន ០១ នាក់						
១	លឹម ស៊ីសឿល	ប	០៧_៥_៦២	មន្ត្រីក្រសួងកសិកម្ម	កសិកម្ម	ខ I 4	១
	ខ_អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០៤ នាក់						
២	ពៅ វ៉ាំ	ប	២៩_៩_៣០	មន្ត្រីក្រុមហ៊ុនចំការកៅស៊ូ	ស្បៀងសាស្ត្រ	ខ I ១	១
៣	ចក់ សំរឿន	ប	២៩_១១_៦៩	គ្រូបង្រៀន	ស្បៀងសាស្ត្រ	ខ I ១	៣
	ឌី សំអាន	ប	១៥_០១_៣១	សិស្ស	ស្បៀងសាស្ត្រ	៩០.ខ I ១	៣
	វ៉ាង ហុង	ប	០១_០១_៣២	សិស្ស	ស្បៀងសាស្ត្រ	៩០. ខ I ១	៣
	គ_អ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០១ នាក់ :						
	[illegible] សុផល	ប	២៧_១១_៦៨	មន្ត្រីក្រសួងកសិកម្ម	ជួសជុល និង ថែទាំ រោយន្ត	ខ II ១	១

២_ក្រសួងពាណិជ្ជកម្មចំនួន ០១ នាក់ :

ក_អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

៧	អ៊ុំ ចាន់ធូ	ប	០៣_០២_៦៩	សិស្ស		ផ្នែកទីផ្សារ	អ០. ខ I ១	២

៣_ក្រសួងសាធារណការ និង ដឹកជញ្ជូនចំនួន ០២ នាក់

ក_អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

៨	គុណ សុវណ្ណរិទ្ធ	ប	២៤_១១_៦៨	សិស្ស	សំណង់	អ០.ខ I ១	៤
៩	ម៉ៅ ពិសិន	ប	០៧_៧_៧៧	សិស្ស	សំណង់ស៊ីវិល និង ឧស្សាហកម្ម	អ០.ខ I ១	១

៤_ក្រសួងសុខាភិបាលចំនួន ០២ នាក់

ក_អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

១០	ស្រី សុជាណេរី	ស្រី	២៣_០២_៦៤	មន្ត្រីក្រសួងសុខាភិបាល	វេជ្ជសាស្ត្រ	ខ I ១	៣
១១	អែម សុធា	ប	១០_១០_៦៩	សិស្ស	វេជ្ជសាស្ត្រ	អ០.ខ I ១	២

៥_ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិចំនួន ០៤ នាក់

ក_អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០៤ នាក់

១២	ហួន សុជាតិ	ប	១៦_៩_៧១	សិស្ស	ទំនាក់ទំនងអន្តរជាតិ	អ០.ខI១	១
១៣	ស៊ុន ស៊ុយ៉ា	ប	១៦_៥_៦៩	សិស្ស	ទំនាក់ទំនងអន្តរជាតិ	អ០.ខI១	១
១៤	ភូវ សុធីរ	ប	២៧_៦_៦៩	មន្ត្រីក្រសួង ការបរទេស	ទំនាក់ទំនងអន្តរជាតិ	ខ I ១	១
១៥	តាម សារ៉ាត់	ប	១៧_៥_៦៩	មន្ត្រីខេត្តបន្ទាយ មានជ័យ	ទំនាក់ទំនងអន្តរជាតិ	ខ I ១	១

៦_ទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ០១ នាក់

ក_អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រភាគ ១ ចំនួន ០១ នាក់

១៦	កែវ ធីរុន	ប	០៥_៦_៦៩	សិស្ស	សេដ្ឋកិច្ច	អ០.ខI ៤	១

បានបញ្ឈប់បញ្ជីត្រឹមចំនួន ១៦ « ដប់ប្រាំមួយ » នាក់ប៉ុណ្ណោះ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស្វាគ៌ា សុខ

* * *

៨- ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

ភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ៩១/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រ ...ប អោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយសេវេន ដេយអាត់វេនទីស្ទ របស់លេ. ឈ្មួ ងឿន ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តសៀមរាប លេខ ២១៦១ ខសរ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមសេវេនដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា « **សេវេនដេយអាត់វេន**

នីស្ថបុសមេឃ » មួយកន្លែងដែលមានទីតាំង ស្ថិតនៅ ឃុំជើងទៀន ស្រុក ចុងកាល់ ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះ « **សេទេនដេយអាត់ទេននីស្ថបុសមេឃ** »ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារ ផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ « **សេទេនដេយអាត់ទេននីស្ថបុសមេឃ** » ត្រូវគោរព និងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឹងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រ កម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹក នាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបាន ល្អជាមួយស្ថាប័នពាក់ព័ន្ធ សំឡាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរី - ភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួល ទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និង សាសនាខេត្តសៀមរាប និង មន្ត្រី រាជការ គ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេច នេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារិទ្ធ

* * *

ភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ៩២/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះ រាជក្រមលេខ នស.រកម ០១៩៦_១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយសេវែនដេយអាត់វេនទីស្ទ របស់លោកស្រី ពៅ ចារី ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តសៀមរាប លេខ ២១៥៩ ខសរ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមសេវែនដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «**សេវេនដេយអាត់វេនទីស្ទគ្រិស្ទភូមិអូរក្រឡាញ់**» មួយកន្លែងដែលមានទីតាំង ស្ថិតនៅភូមិអូរក្រឡាញ់ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះ « **សេចក្ដីសង្គ្រោះដោយសារតែសេចក្ដីជំនឿលើព្រះគ្រិស្ទ** »ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ « **សេចក្ដីសង្គ្រោះដោយសារតែសេចក្ដីជំនឿលើព្រះគ្រិស្ទ** » ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនានិង សណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនាខេត្តសៀមរាប និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចន្ទវង្ស

* * *

ភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ : ៩៣/៩៧ ក.ធ.ស

***

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយសេវែនដេយអាត់វេនទីស្ទ របស់លោក ចៀប កាន់ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្ដម អភិបាល ខេត្តសៀមរាប លេខ ០៣០៨ ខសរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមសេវែនដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា « **សេវែនដេយអាត់វេនទីស្ទភូមិតាកាំ** » មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិតាកាំ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះ « **សេចក្ដីសង្គ្រោះដោយអាត់មេន ទីស្ថានមិតាភាព** » ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ « **សេចក្ដីសង្គ្រោះដោយអាត់មេនទីស្ថានមិតាភាព** » ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនានិង សណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនាខេត្តសៀមរាប និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចន្ទារិទ្ធ

* * *

ភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ : ៩៤/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ចស/រកម ០១៩៦-១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជាឈ្មោះ « សម្ព័ន្ធកិច្ចប្រ៊ែសប៊ីធីរានខ្មែរ » របស់លោក យោក គន្ធាសម្បូរណ៍ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៧ ។
- បានឃើញលិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំងរបស់ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ លេខ ១០០២ លសស ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជា នៃព្រះវិហារឈ្មោះហៅថា « **សម្ព័ន្ធកិច្ចប្រ៊ែសប៊ីធីរានខ្មែរ** » មួយកន្លែងដែលមានទីតាំងស្នាក់ការកណ្តាល ស្ថិតនៅផ្ទះលេខ ១៤៤ ផ្លូវលេខ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ នៃព្រះវិហារឈ្មោះ « **សម្ព័ន្ធកិច្ចប្រ៊ែសប៊ីធីរានខ្មែរ** » ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ « **សម្ព័ន្ធកិច្ចប្រ៊ែសប៊ីធីរានខ្មែរ** » ត្រូវគោរព និងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃស្នាក់

ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនង អោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការ និង សាសនារាជធានីភ្នំពេញនិង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ធណ្ណរ័ត្ន

* * *

ភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ៩៥/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម. ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។

- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការ ថ្នាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជាឈ្មោះ « ព្រះវិហារទីសលីយាន » របស់លោក ណាជូ រ៉ាហ្វែល ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ។
- បានឃើញលិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំងរបស់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ លេខ ៥៥៧ លសស ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជានៃព្រះវិហារឈ្មោះហៅថា « **ទីសលីយាន** » មួយកន្លែងដែលមានទីតាំងស្នាក់ការកណ្តាល ស្ថិតនៅផ្ទះលេខ ៤៤២B ផ្លូវ ព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ នៃព្រះវិហារឈ្មោះ «**ទីសលីយាន** » ត្រូវអនុញ្ញាត អោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ « **ទីសលីយាន** » ត្រូវគោរព និងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្សាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿ សាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនារាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន ចណ្ណារ័ត្ន

* * *

ភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ : ៩៦/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ចស.រកម ០១៩៦_១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ឆស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជាឈ្មោះ «**ព្រះវិហារនិងបណ្ណាល័យជំនឿនិងសន្តិ**» របស់លោក **សេត ថេង** ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។

– បានឃើញលិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំង របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ លេខ ៤៤៦ លេសស ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជា នៃព្រះវិហារឈ្មោះហៅថា «**ព្រះវិហារនិងបណ្ណាល័យដំណឹងល្អ**» មួយកន្លែងដែលមាន ទីតាំងស្នាក់ការកណ្តាល ស្ថិតនៅផ្ទះលេខ ១៣៩Eo ផ្លូវលេខ ២១៧ សង្កាត់អូរឫស្សីទី ៣ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ នៃព្រះវិហារឈ្មោះ « **ព្រះវិហារនិងបណ្ណាល័យ ដំណឹងល្អ** »ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ « **ព្រះវិហារនិងបណ្ណាល័យដំណឹងល្អ** » ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់រៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនារាជធានីភ្នំពេញ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ហៀង ចណ្ណារ៉ឿ

ភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ៩៧/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមសហព័ន្ធគ្រិស្តបរិស័ទខ្មែរឈ្មោះ « ដាប់ធីស្ទគ្គីពេញ » របស់លោក **ឆោ ឈើល** ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។
- បានឃើញលិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំង របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ លេខ ៤៨៧ លេសស ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

: អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមសហព័ន្ធគ្រិស្តបរិស័ទខ្មែរនៃព្រះវិហារឈ្មោះហៅថា « **ដាប់ធីស្ទគ្គីពេញ** » មួយកន្លែងដែលមានទីតាំងស្នាក់ការស្ថិតនៅ ផ្ទះលេខ ១៨E_0 ផ្លូវលេខ ២៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ នៃព្រះវិហារឈ្មោះ « **បាបទីស្ទភ្នំពេញ** » ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនា គ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ « **បាបទីស្ទភ្នំពេញ** » ត្រូវគោរព និងអនុវត្តន៍អោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនារាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារ៉ែ

* * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល